# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៦

**អនុក្រឹត្យ លេខ ០១ អនក្រ.បក**

**ស្តីពីបទបញ្ជាផ្ទៃក្នុង**

**ក្រុមប្រឹក្សាភិបាលអាជ្ញាធរ « អប្សរា »**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដីនគរោបនី យកម្ម និង សំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ០០១ នស ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីអំពីការ រៀបចំតំបន់ និង ការគ្រប់គ្រងតំបន់សៀមរាបអង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និង រៀបចំតំបន់អង្គរ (អាជ្ញាធរអប្សរា)
- តាមសំណើរបស់អគ្គនាយកអាជ្ញាធរ « អប្សរា »

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** សមាសភាពនៃក្រុមប្រឹក្សាភិបាល សមាសភាពនៃប្រធាន និង អនុប្រធានដែលបានបញ្ជាក់ក្នុងមាត្រា ទី៥ នៃព្រះរាជក្រឹត្យលេខ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត អាជ្ញាធរ « អប្សរា » ។

**មាត្រា ២ :** ប្រភេទនៃការពិភាក្សាសំរេច ដែលបានបញ្ជាក់នៅក្នុងមាត្រាទី ៦ នៃ ព្រះរាជក្រឹត្យលេខ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរ « អប្សរា » ។

**មាត្រា ៣ :** ចំនួនសម័យប្រជុំប្រចាំឆ្នាំ របៀបបែបបទ នៃការធ្វើសេចក្ដីសំរេចដូចដែលមានចែងក្នុងមាត្រា ៧ នៃព្រះរាជក្រឹត្យ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរ «អប្សរា» ។

## ជំពូកទី ២

## លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាល

**មាត្រា ៤ :** លេខាធិការដ្ឋានផ្នែករដ្ឋបាលនៃក្រុមប្រឹក្សាភិបាលត្រូវទទួលបន្ទុកដោយភ្នាក់ងារម្នាក់នៃរាជអាជ្ញាធរ «អប្សរា» តាមបញ្ជាអនុប្រធានដែលមានការព្រមព្រៀងពីអគ្គនាយក ។

**មាត្រា ៥ :** ការិយាល័យនៃក្រុមប្រឹក្សាភិបាល មានសមាសភាពដូចតទៅ ÷

- ទេសរដ្ឋមន្ត្រីទទួលបន្ទុក វប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ជាប្រធាន
- អនុប្រធាន ២ នាក់
- អភិបាលខេត្តសៀមរាប ឬ តំណាង
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តំណាង

ការិយាល័យត្រៀមរៀបចំសេចក្ដីសំរេចនានារបស់ក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាល អាចវិលែកអំណាចខ្លះ ក្នុងការធ្វើសេចក្ដីសំរេចអោយទៅការិយាល័យជា

អាទិ៍គី ការងារសំខាន់ៗផ្នែក ហិរញ្ញវត្ថុ ការជ្រើសរើសបុគ្គលិកសំខាន់ៗព្រមទាំងតាមដានអោយបានទៀងទាត់នូវសកម្មភាពរបស់អាជ្ញាធរ « អប្សារា » ។
អគ្គនាយកដោយមានជំនួយការពីនាយកហិរញ្ញវត្ថុផង រៀបចំព្រមទាំងដាក់ជូននូវសំណុំរឿងផ្សេងៗ អោយការិយាល័យពិនិត្យ ។ ស្នងការគណនីរួមប្រជុំការិយាល័យរាល់ពេលណាដែលត្រូវការ ។

**មាត្រា ៦ :** ចំណាយក្នុងដំណើរការនៃក្រុមប្រឹក្សាភិបាល ត្រូវរ៉ាប់រងតាមឥណទានដែលបើកឡើងជារៀងរាល់ឆ្នាំក្នុងថវិកាអាជ្ញាធរ « អប្សារា » ។

## ជំពូកទី ៣

## ការដំណើរការ

**មាត្រា ៧ :** របៀបវារៈត្រូវបញ្ជូនទៅអោយសមាជិកទាំងអស់ យ៉ាងហោចណាស់ក៏១០ថ្ងៃមុនដែរ។

**មាត្រា ៨ :** ពេលមានប្រជុំក្រុមប្រឹក្សាភិបាល សមាជិកដែលមានវត្តមានត្រូវចុះហត្ថលេខានៅលើបញ្ជីវត្តមាន ។ កាលបើសមាជិកណាមួយខកខានពុំបានចូលរួមក្នុងអង្គប្រជុំ តែបានប្រគល់អំណាចអោយទៅសហសេវិកម្នាក់របស់ខ្លួន សិទ្ធិអំណាចនោះត្រូវភ្ជាប់ទៅជាមួយនឹងបញ្ជីវត្តមានផង ។

**មាត្រា ៩ :** ប្រឹក្សាភិបាលអាចបើកសម័យប្រជុំឡើងបានលុះត្រាតែ ២/៣ នៃចំនួនសមាជិកបានមករួមប្រជុំ ឬ ប្រគល់អំណាចអោយសហសេវិកម្នាក់ទៀត ។

**មាត្រា១០ :** ក្រុមប្រឹក្សាភិបាលអាចប្រគល់អំណាចទាំងស្រុង ឬ មួយភាគក្នុងការសំរេចផ្សេងៗទៅដល់អគ្គនាយក លើកលែងតែអំណាចទាំងប៉ុន្មានដែលកំណត់នៅមាត្រាទី ៦ នៃព្រះរាជក្រឹត្យ នស រកត ០២៩៥/១២ ចុះថ្ងៃទី ១៩ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ « អប្សារា » ។

**មាត្រា ១១:** ការបោះឆ្នោតធ្វើឡើងដោយលើកដៃ ។ ក្នុងករណីដែលចំនួនអ្នកមកប្រជុំ ឬ អ្នកទទួលអំណាចបោះឆ្នោតពុំគ្រប់ ២/៣ នៃសេចក្តីសំរេចដែលចែងនៅក្នុងរបៀបវារៈពេលនោះ អាចយកទៅធ្វើ នៅសម័យប្រជុំលើកក្រោយ បន្ទាប់ពីមានការកោះហៅត្រឹមត្រូវតាមបែបបទ ។ សេចក្តីសំរេចនោះ ត្រូវទទួលសំលេងភាគច្រើនដាច់ខាត នៃសមាជិកដែលមកប្រជុំ ។

**មាត្រា១២** : សេចក្ដីសំរេចត្រូវអនុម័តឡើង កាលណាបានទទួលសំលេងភាគច្រើនដាច់ខាតនៃសមាជិកដែលបានមកប្រជុំ ឬ ដែលបានប្រគល់អំណាចបោះឆ្នោតដល់សមាជិកម្នាក់ទៀត ។ សេចក្ដីសំរេចទាំងប៉ុន្មានអាចធ្វើទៅបានលុះត្រាតែយ៉ាងហោចណាស់ ២/៣ នៃសមាជិកបានចូលរួម ឬ បានប្រគល់អំណាចបោះឆ្នោត ។

**មាត្រា១៣** : កំណត់ហេតុនៃសម័យប្រជុំនីមួយៗ ត្រូវធ្វើឡើងដោយលេខាធិការដ្ឋានរដ្ឋបាលក្រោមនិវាទ នៃ សហប្រធានទាំង ២ ឬ ក្រោមនិវាទអនុប្រធានដែលបានទទួលអំណាចពីសហប្រធាន ។ កំណត់ហេតុនោះមានចុះឈ្មោះសមាជិកដែលមានវត្តមាន ឬ ដែលបានប្រគល់អំណាចតំណាងបុគ្គល ដទៃ ដែលមកចូលរួមក្នុងសម័យប្រជុំព្រម ទាំងសេចក្ដីសំរេចដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល ។ កំណត់ហេតុត្រូវផ្សព្វផ្សាយទៅដល់រាល់សមាជិកនៃក្រុមប្រឹក្សាភិបាល ព្រមទាំងបុគ្គលដទៃដែលមានវត្តមាននៅអង្គប្រជុំដែលពោលខាងលើ យ៉ាងហោចណាស់ ១០ ថ្ងៃ មុនសម័យប្រជុំបន្ទាប់ ។

កំណត់ហេតុទាំងឡាយ ត្រូវទទួលសេចក្ដីយល់ព្រម នៅពេលផ្ដើមសម័យប្រជុំបន្ទាប់ ។

ឯកសារចំលង ឬ ឯកសារដកស្រង់នៃកំណត់ហេតុដែលត្រូវបង្ហាញចំពោះមុខអាជ្ញាធរតុលាការ ត្រូវប្រធានចុះហត្ថលេខា ទោះជាប្រធានបានរួមចំណែក ឬ មិនបានរួមចំណែកក្នុងការពិភាក្សា សំរេចក៏ដោយ ។

**មាត្រា១៤** : សមាជិកទាំងឡាយនៃក្រុមប្រឹក្សាភិបាលពុំអាចរក ឬ រក្សាទុកនូវផលប្រយោជន៍ណាមួយ ពុំអាចទទួលមុខងារណាមួយនៅក្នុងសហគ្រាសទាំងឡាយណាដែលទទួលការងារអំពីអាជ្ញាធរ «អង្គរា» ក្នុងការសាងសង់ក្ដី ក្នុងការផ្ដល់ភស្តុភារក្ដី ។ ម៉្យាងវិញទៀតសមាជិកទាំងនោះក៏ពុំអាចទទួល ជាកំរៃអ្វីមួយប្រសិនបើខ្លួនបានបំរើការដោយប្រការណាក្ដីចំពោះសហគ្រាសនោះ ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

**មាត្រា ១៥** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦** : អាជ្ញាធរ « អប្សារា » មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

**នាយករដ្ឋមន្ត្រីទី ១**
**ព្រះហស្តលេខា និងត្រា**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហត្ថលេខា និងត្រា**
**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

**អនុក្រឹត្យ លេខ ០២ អនក្រ.បក**

**ស្តីពីការកែសម្រួលទំហំដី តំបន់ឧស្សាហកម្មស្ទឹងហាវ**

**ក្រុងព្រះសីហនុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតតំបន់ឧស្សាហកម្មស្ទឹងហាវ ក្រុងព្រះសីហនុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល និង តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម